# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ១៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥ ។

## សម្រេច

**មាត្រា ១ ..**

បង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ហៅកាត់ថា " **គ.ជ.អ** " ក្នុងគោលបំណងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការនានា ដែលពាក់ព័ន្ធព្រមទាំងធ្វើការទប់ស្កាត់ នូវលំហូរចូលនៃជនអនាថាមកទីក្រុង ឬ ទីប្រជុំជន និង ឆ្លងដែនទៅប្រទេសជិតខាង គ្រប់គ្រង ដោះស្រាយបញ្ហាជនអនាថានៅទូទាំងប្រទេសស្របតាមគោលនយោបាយសេវាសង្គមកិច្ច ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការធ្វើសមាហរណកម្មទៅតាមសហគមន៍ ។

**មាត្រា ២ ..**

ជនអនាថា គឺជាជំពូកជនទីទ័លក្រ ដែលគ្មានទីជម្រក តែលតោល គ្មានទីពឹង ។

**គ.ជ.អ** អាចកំណត់មុខសញ្ញាជនអនាថា តាមការជាក់ស្តែងថែមទៀតបាន ។

**មាត្រា ៣ ..**

គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា មានសមាសភាព ដូចតទៅ ÷

| | | |
|---|---|---|
| ១-រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | | ប្រធាន |
| ២-រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | ០១ រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ០១ រូប | អនុប្រធាន |
| ៤- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ០១ រូប | អនុប្រធាន |
| ៥-រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ | ០១ រូប | អនុប្រធាន |
| ៦-អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | សមាជិក |
| ៧-អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | ០១ រូប | សមាជិក |
| ៨- អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | ០១ រូប | សមាជិក |
| ៩- អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និង កីឡា | ០១ រូប | សមាជិក |
| ១០- អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ០១ រូប | សមាជិក |
| ១១- អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | ០១ រូប | សមាជិក |
| ១២- អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | ០១ រូប | សមាជិក |
| ១៣-អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១ រូប | សមាជិក |
| ១៤- អនុរដ្ឋលេខាធិការ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | ០១ រូប | សមាជិក |
| ១៥-អនុរដ្ឋលេខាធិការ ក្រសួងផែនការ | ០១ រូប | សមាជិក |
| ១៦-អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ | | សមាជិក |
| ១៧-តំណាងគណៈកម្មាធិការ កាកបាទក្រហមកម្ពុជា | ០១ រូប | សមាជិក |

ការតែងតាំងសមាសភាព **គ.ជ.អ** ខាងលើនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៤ ..**

**គ.ជ.អ** មានតួនាទី ជាសេនាធិការ ឱ្យរាជរដ្ឋាភិបាល និង មានភារកិច្ច ដូចខាងក្រោម ÷

១-បង្កើតឱ្យមានយុទ្ធសាស្ត្ររួម សម្រាប់ដោះស្រាយបញ្ហាជនអនាថា ដោយរួមបញ្ចូលការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និងបង្ការទប់ស្កាត់ ការវិលត្រឡប់មកសុំទានវិញ ។

២-ពង្រឹងពង្រីកបណ្តាញការងារសម្រាប់ជនអនាថានៅគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សេវាដល់ជនទាំងនោះឱ្យមាន

លំនឹងក្នុងការកសាងជីវភាពរស់នៅដោយខ្លួនឯង ។

៣-ផ្តល់ឱកាសឱ្យជនអនាថាមានជម្រកសុវត្ថិភាព ស្នាក់នៅបណ្តោះអាសន្ន ដើម្បីទទួលបានការផ្គត់ផ្គង់ជីវភាព ការថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និង ធ្វើការដឹកជញ្ជូនជនទាំងនោះ ឱ្យបានដល់មូលដ្ឋានគោលដៅរស់នៅអចិន្ត្រៃយ៍របស់គេ ។

៤-កសាងផែនការថវិកាជាតិប្រចាំឆ្នាំ សម្រាប់ចំណាយលើការងារសេវាដល់ជនអនាថា ដោយបញ្ចូលក្នុងខ្ទង់ចំណាយថវិកា របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង ទំនាក់ទំនងស្វែងរកថវិកាពីប្រភពផ្សេងៗទៀត ។

៥-ត្រួតពិនិត្យ និង វាយតម្លៃលទ្ធផល ការអនុវត្តគោលការណ៍ ផែនការ កម្មវិធី និង គម្រោងនានា ព្រមទាំងគ្រប់គ្រងស្ថិតិ និង បូកសរុបលទ្ធផលការងារដោះស្រាយបញ្ហាជនអនាថាប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល ។

**មាត្រា ៥ ..**

សមាជិក គ.ជ.អ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីចាំបាច់ប្រធាន គ.ជ.អ អាចអញ្ជើញតំណាងអង្គការជាតិ អន្តរជាតិ ពាក់ព័ន្ធចូលរួមប្រជុំបាន ។

គណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ។

**មាត្រា ៦ ..**

គ.ជ.អ មាននាយកដ្ឋានសុខុមាលភាពសង្គមនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍ ។

**មាត្រា ៧ ..**

បង្កើតអនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថា ខេត្ត ក្រុង ទូទាំងប្រទេស នៅក្រោមឱវាទ គ.ជ.អ ដែលទទួលបន្ទុកអនុវត្តនូវភារកិច្ចរបស់ គ.ជ.អ តាមបណ្តាខេត្តក្រុងនីមួយៗ ហើយដែលមានសមាសភាពដូចតទៅ ÷

| | |
|---|---|
| ១-អភិបាលខេត្ត ក្រុង | ប្រធាន |
| ២-អភិបាលរងទី១ ខេត្ត ក្រុង | អនុប្រធាន |
| ៣-ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង | សមាជិកអចិន្ត្រៃយ៍ ជាប្រធានលេខាធិការដ្ឋាន |
| ៤-ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត ក្រុង | សមាជិក |
| ៥-ប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្ម និង សំណង់ ខេត្ត ក្រុង | សមាជិក |
| ៦-ប្រធានខុទ្ទកាល័យ ខេត្ត ក្រុង | សមាជិក |
| ៧-ប្រធានមន្ទីរសុខាភិបាល ខេត្ត ក្រុង | សមាជិក |
| ៨-ប្រធានមន្ទីរអប់រំ យុវជន និង កីឡា | សមាជិក |
| ៩-ប្រធានមន្ទីរកិច្ចការនារី ខេត្ត ក្រុង | សមាជិក |

១០-ប្រធានមន្ទីរព័ត៌មាន ខេត្ត ក្រុង — សមាជិក

១១-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត ក្រុង — សមាជិក

១២-ប្រធានមន្ទីរទេសចរណ៍ ខេត្ត ក្រុង — សមាជិក

១៣-ប្រធានមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត ក្រុង — សមាជិក

១៤-ប្រធានមន្ទីរផែនការ ខេត្ត ក្រុង — សមាជិក

១៥-តំណាងគណៈកម្មាធិការ សាខាកាកបាទក្រហម ខេត្ត ក្រុង — សមាជិក

-អនុគណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ ខេត្ត ក្រុង ។

-ត្រូវរៀបចំលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ។

**មាត្រា ៨ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩ ..**

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា១០ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង សមាជិក គ.ជ.អ ព្រមទាំងសមាជិកអនុគណៈកម្មាធិការ ដូចមានចែងក្នុងមាត្រា ៣ និង មាត្រា ៧ ខាងលើ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ